ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សាលក្រមលេខ ៨២ (ង)

ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣

**ដោយមានសមាសភាព**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៤១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបណ្តឹងទាស់របស់ជនជាប់ចោទ៖

ឈ្មោះ [redacted] វុំង ភេទប្រុស កើតនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តពោធិ៍សាត់ និងទីលំនៅបច្ចុប្បន្ននៅភូមិក្រាំងវែង ឃុំខ្នារកន្សួរ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ [redacted] មិញ (រស់) ម្តាយឈ្មោះ [redacted] សុខជៀន (រស់) ប្រពន្ធឈ្មោះ [redacted] សុភាព (រស់) មានកូនចំនួន០១នាក់ ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិផ្លុកទ្រូ ឃុំផ្លុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វុំង ។



Scanned with CamScanner

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១០៧៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

- **បានឃើញ** ដីកាបញ្ជូនទៅជំនុំជម្រះលេខ ២១៦ (ក) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

- **បានឃើញ** ដីកាចាត់តាំងចៅក្រមប្រឹក្សាជំនុំជម្រះលេខ ៣៨៦ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

- **បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៦៧ (ង) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

## អង្គហេតុដែលប្ដឹងមកតុលាការ

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ស៊ីនាង (ជ្រូក) ដោយពាក់ព័ន្ធនឹងថ្នាំញៀន ។ ក្រោយធ្វើការសាកសួររួចឈ្មោះ [redacted] ស៊ីនាង (ជ្រូក) បានសហការជាមួយសមត្ថកិច្ចធ្វើការញុះញង់បន្ត ។ លុះដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចខេត្តកំពង់ឆ្នាំង បានសហការជាមួយសមត្ថកិច្ចខេត្តពោធិ៍សាត់បន្តឃាត់ខ្លួនឈ្មោះ [redacted] ពន្លក ដោយឈ្មោះនេះជាអ្នកយកថ្នាំញៀនមកទម្លាក់ឱ្យឈ្មោះ [redacted] ស៊ីនាង (ជ្រូក) នៅត្រង់ចំណុចកន្ទួរ ស្ថិតនៅភូមិផ្អុកទ្រូ ឃុំផ្អុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ ឈ្មោះនេះឆ្លើយថាចំពោះថ្នាំញៀន គឺខ្លួនទិញពីឈ្មោះ [redacted] វ៉ុង ភេទប្រុស អាយុ៣០ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិកណ្ដាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ និងឈ្មោះ [redacted] ម៉ឺន ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិត្រពាំងកន្ទួត ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ចំណែកឈ្មោះ [redacted] ឆេងហួ ជាក្រុមតែមួយជាមួយខ្លួន ។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានសរុបទាំងអស់ចំនួន ១១កញ្ចប់ (សារធាតុញៀនចំនួន ១២.១១ ក្រាម មិនគិតសំបកផង់ ជារបស់ឈ្មោះ [redacted] ស៊ីនាង និងសារធាតុញៀនចំនួន ១១.១៩ ក្រាម មិនគិតសំបកផង់ ជារបស់ឈ្មោះ [redacted] ពន្លក) ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] វ៉ុង បានឆ្លើយថា៖ ខ្ញុំបាទសូមបដិសេធចោលនូវការចោទប្រកាន់មកលើរូបខ្ញុំបាទថា ខ្ញុំបាទបានជួញដូរថ្នាំញៀន ពីព្រោះខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទនោះទេ ។ ចំពោះឈ្មោះ [redacted] ពន្លក, ឈ្មោះ [redacted] ស៊ីនាង និងឈ្មោះ [redacted] ឆេងហួ ខ្ញុំបាទមិនដែលស្គាល់អ្នកទាំងនេះទេ ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្ញុំបាទនៅផ្ទះជាមួយប្រពន្ធកូន និងសាច់ញាតិ មិនបានទៅណាទេ ហើយពីរបីថ្ងៃមុននេះក៏ខ្ញុំបាទមិនបានទៅណាដែរ ។ ចំពោះលេខទូរស័ព្ទរបស់ខ្ញុំបាទ គឺប្រើលេខ ០៩៧ ៥៥ ៦៦ ២៧១ ហើយចំពោះអត្តសញ្ញាណប័ណ្ណ គឺខ្ញុំបាទបានបាត់ប្រហែលជាងពីរឆ្នាំមុន ដោយខ្ញុំបាទទើបតែធ្វើថ្មីទេ ។ ខ្ញុំបាទមិនចេះប្រើប្រាស់ថ្នាំញៀននោះទេ ។

- សាក្សីឈ្មោះ[redacted] ពន្លក បានឆ្លើយថា៖ ខ្ញុំបាទអត់ស្គាល់អ្នកលក់ ឬអ្នកទិញថ្នាំញៀននោះទេ ហើយចំពោះចម្លើយរបស់ខ្ញុំដែលឆ្លើយពីមុននោះ គឺខ្ញុំបាទមានការភ័យខ្លាចនឹងសមត្ថកិច្ច ។ ខ្ញុំបាទ ពុំដែលស្គាល់ឈ្មោះ [redacted] ស៊ីនាង ទេ តែចំពោះឈ្មោះ [redacted]ហួ គឺជាក្មួយរបស់ខ្ញុំ តែខ្ញុំមិនដឹងថា ឈ្មោះ [redacted]ហួ បានជួញដូរ ឬប្រើប្រាស់ថ្នាំ



Scanned with CamScanner

ញៀន ឬក៏អត់នោះទេ ។ ចំពោះឈ្មោះ [redacted] រ៉ុង ដែលបានបង្ហាញខ្លួននៅក្នុងថ្ងៃដែលតុលាការជំនុំជម្រះនេះ គឺខ្ញុំបាទមិនដែលស្គាល់នោះទេ ។

- អំណានចម្លើយរបស់ឈ្មោះ [redacted] ពន្លក នៅដំណាក់កាលស៊ើបសួរ បានឆ្លើយថា៖ ខ្ញុំបាទធ្លាប់លក់ថ្នាំញៀនជាច្រើនឆ្នាំហើយ តែឈប់មួយរយៈ ទើបតែខែមករា ឆ្នាំ២០២៣ នេះ ខ្ញុំបាទលក់វិញ ។ ថ្នាំញៀននេះ ខ្ញុំបាទទិញពីឈ្មោះ រ៉ុង រស់នៅឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដោយទិញម្តងៗក្នុងតម្លៃ ៤០០.០០០ (សែសិបម៉ឺន) រៀល ហើយលក់បន្តក្នុងតម្លៃ ៥០០.០០០ (ហាសិបម៉ឺន) រៀល ទៅឱ្យឈ្មោះ [redacted] ស៊ីនាង ហៅ ជ្រូក រស់នៅឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្ញុំកំពុងតែធ្វើផ្ទះនៅចំណុចភូមិបេង ឃុំខ្នារអន្ទ្វារ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក៏មានឈ្មោះ [redacted] ឆេងហួ បានឱ្យលុយមកខ្ញុំបាទដើម្បីរកទិញថ្នាំញៀន រួចលក់បន្តឱ្យឈ្មោះ [redacted] ស៊ីនាង ដើម្បីយកប្រាក់ចំណេញ ។ នៅពេលដែលប៉ូលីសចាប់ខ្ញុំបាទ គឺគ្មានគ្រឿងញៀននោះទេ ហើយប៉ូលីសចាប់ខ្ញុំបាទបញ្ជូនមកដោយសារឈ្មោះ ជ្រូក ឆ្លើយដាក់រូបខ្ញុំបាទ ។ ខ្ញុំបាទសំណូមពរតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យរូបខ្ញុំបាទផង ។

- អំណានលទ្ធផលកោសលវិច័យសំណាកដែលសង្ស័យថា ជាគ្រឿងញៀន របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ៤១៥២១/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ បានបញ្ជាក់ថា៖ សំណាកជាគ្រឿងញៀនប្រភេទម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧៧,២០% នៃទម្ងន់សរុប , វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ **(សំណាកដែលដកហូតពីម្សៅក្រាមសថ្លាសង្ស័យជាសារធាតុញៀនមានទម្ងន់ចំនួន ១១.១៩ ក្រាម មិនគិតសំបកថង់ របស់ឈ្មោះ [redacted] ពន្លក )**

- តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ និងសាក្សី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា ការឆ្លើយរបស់ជនជាប់ចោទ និងសាក្សី គឺពុំមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនោះទេ ។ ហេតុនេះ តំណាងអយ្យការស្នើសុំចៅក្រមជំនុំជម្រះពិនិត្យ និងសម្រេចទៅតាមផ្លូវច្បាប់ ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ុង បានធ្វើសេចក្តីសន្និដ្ឋានថា៖ នៅក្នុងរឿងនេះ ឃើញថា កូនក្តីរបស់ខ្ញុំបាទ ពុំស្គាល់ជនជាប់ចោទផ្សេងទៀតនោះទេ ហើយថ្នាំដែលដកហូតបាននោះក៏មិនមែនជារបស់កូនក្តីរបស់ខ្ញុំបាទដែរ ។ ហេតុនេះ គឺមិនមានធាតុផ្សំគ្រប់គ្រាន់ដើម្បីដាក់បន្ទុកមកលើកូនក្តីរបស់ខ្ញុំបាទនោះទេ ។ ដូច្នេះ ខ្ញុំបាទស្នើសុំតុលាការសូមលើកលែងការចោទប្រកាន់មកលើកូនក្តីរបស់ខ្ញុំបាទផង ។

- ជនជាប់ចោទឈ្មោះ [redacted] រ៉ុង បានកត់សម្គាល់/សំណូមពរថា៖ សូមតុលាការជួយលើកលែងចោទប្រកាន់ដល់រូបខ្ញុំផង ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់អំណានលទ្ធផលកោសលវិច័យ



Scanned with CamScanner

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់ការកត់សម្គាល់/សំណូមពររបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ុង បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ គឺថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០២៣ ខ្លួនបាននៅផ្ទះជាមួយប្រពន្ធ និងកូន មិនបានទៅណានោះទេ ហើយខ្លួនក៏មិនដែលស្គាល់ឈ្មោះ [redacted] ពន្លក, ឈ្មោះ [redacted] ឆេងហួ និងឈ្មោះ [redacted] ស៊ីនាង នោះទេ ។ រីឯសាក្សីឈ្មោះ [redacted] ពន្លក បានបញ្ជាក់ថា៖ ចំពោះឈ្មោះ មិញ វ៉ុង ដែលបានបង្ហាញខ្លួននៅចំពោះមុខរូបខ្លួននេះ គឺខ្លួនពុំដែលស្គាល់ទេ ហើយក៏ពុំដែលធ្លាប់បានទិញលក់ថ្នាំញៀនអ្វីជាមួយគាត់នោះដែរ ។ ប៉ុន្តែ តាមចម្លើយរបស់ឈ្មោះ [redacted] ពន្លក ដែលបានឆ្លើយនៅដំណាក់កាលកន្លងមក បានបញ្ជាក់ថា៖ ខ្លួនបានទិញពីឈ្មោះ វ៉ុង ភេទប្រុស នៅខេត្តពោធិ៍សាត់ ក្នុងម្តង១តម្លៃ ៤០០.០០០ (សែបសិបម៉ឺន) រៀល ។

- ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សីខាងលើនេះ រួមជាមួយនឹងភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ មិញ វ៉ុង ពិតជាបានប្រព្រឹត្តអំពើជួញដូរនូវសារធាតុញៀនដូចការចោទប្រកាន់មែន ។

- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ុង ធ្វើឡើងដោយចេតនា ហើយអំពើនេះបានធ្វើឱ្យខូចសណ្តាប់ធ្នាប់សង្គម សន្តិសុខ របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់សុខភាពអ្នកដទៃ ដែលត្រូវបានច្បាប់ការពារ និងតម្រូវឱ្យផ្តន្ទាទោស ។

- មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] វ៉ុង ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិផ្លុកទ្រូ ឃុំផ្លុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ។

- តាមរយៈពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] វ៉ុង គឺបានប្តឹងទាស់ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៧ (ង) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើរូបខ្លួនចំនួន ០២ (ពីរ) ឆ្នាំ ដោយសារខ្លួនមិនសុខចិត្តទៅនឹងការសម្រេចនេះ ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ដោយឡែក តាមការពិនិត្យទៅលើអង្គហេតុ និងភស្តុតាង ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] វ៉ុង ដូចការចោទប្រកាន់មែន ។ ប៉ុន្តែដោយសារជនជាប់ចោទឈ្មោះ [redacted] វ៉ុង មិនធ្លាប់មានការផ្តន្ទាទោសពីមុនមក ចំណែកទោសដែលតុលាការនឹងប្រកាសចំពោះជនជាប់ចោទនោះ គឺជាទោសដាក់ពន្ធនាគារដែលមានថិរវេលាតិចជាង ៥ (ប្រាំ) ឆ្នាំ ។ ម្យ៉ាងទៀត ឃើញថា ជនជាប់ចោទបានចូលមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការតាំងពីដំណាក់កាលស៊ើបសួរ និងជំនុំជម្រះ

ជំនុំជម្រះ ដោយពុំមានចេតនាគេចវេះនោះទេ ។ ហេតុនេះ គប្បីតុលាការពិចារណាពីការព្យួរទោសធម្មតាតាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

កែប្រែសាលក្រមព្រហ្មទណ្ឌលេខ ៦៧ (ង) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ត្រង់ចំណុច ២.គ នៃសេចក្តីសម្រេច របស់សាលាដំបូងខេត្តកំពង់ឆ្នាំង មកជា៖

ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វ៉ុង ភេទប្រុស (មានអត្តសញ្ញាណដូចខាងលើ) **ដាក់ពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំ តែទោសនេះ ត្រូវអនុវត្តព្យួរធម្មតា** ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិផ្អកទ្រូ ឃុំផ្អកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ។ (ក្រៅឃុំ)

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈដោយចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ុង និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ។ ភាគី មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ឆ្នាំង,ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner